# ខ្លឹមសារនៃព្រឹត្តិបត្រព័ត៌មានគំរូស្តីពីការបន្ត Medicaid

*បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 16 ខែឧសភា ឆ្នាំ 2023*

*បរិបទ*

ជាលើកដំបូងចាប់តាំងពីមុនការរាតត្បាតជំងឺជាសកល ការបន្ត Medicaid បានចាប់ផ្តើមឡើងវិញនៅរដ្ឋ Rhode Island នៅថ្ងៃទី 1 ខែមេសា។ លើសពីភាគបីនៃប្រជាជនរស់នៅរដ្ឋ Rhode Island នាបច្ចុប្បន្ននេះ ទទួលបានការធានារ៉ាប់រង Medicaid។ នៅឆ្នាំបន្ទាប់ ការិយាល័យប្រតិបត្តិនៃសេវាសុខាភិបាល និងមុស្សជាតិ (Executive Office of Health and Human Services, EOHHS) នៃរដ្ឋ Rhode Island—ទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធី Medicaid របស់រដ្ឋ —កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេវាកម្មមនុស្សជាតិ (Department of Human Services, DHS) និង HealthSource RI (HSRI) ដើម្បីធានាបាននូវដំណើរការបន្តដោយរលូន។

អ្នកគឺជាប្រភពព័ត៌មានដែលអាចទុកចិត្តបានសម្រាប់មនុស្សដែលអ្នកបម្រើនៅក្នុងកម្មវិធីផ្សេងៗរបស់ទីភ្នាក់ងាររបស់អ្នក។ តាមរយៈការជួយយើងផ្សព្វផ្សាយអំពីការបន្ត Medicaid អ្នកអាចជួយរដ្ឋ Rhode Island រក្សាអត្រាការធានារ៉ាប់រងសុខភាពខ្ពស់របស់យើង (ប្រហែល 97% នៃរដ្ឋរបស់យើង)។

**នេះគឺជាសារមួយចំនួនអំពីការបន្ត Medicaid យើងសង្ឃឹមថាអ្នកនឹងចែករំលែកតាមរយៈព្រឹត្តិបត្ររបស់ទីភ្នាក់ងាររបស់អ្នកទៅកាន់អ្នកតំណាង ដៃគូសហគមន៍ និងអ្នកផ្តល់សេវាថែទាំសុខភាព។**

---

*សារសម្រាប់ព្រឹត្តិបត្រដែលបានផ្ញើទៅអ្នកតំណាង*

## តើអ្នកទទួលបានការធានារ៉ាប់រងដោយ Medicaid មែនទេ?

*អ្វីដែលអ្នកត្រូវដឹងអំពីការបន្ត Medicaid របស់អ្នក*

នៅថ្ងៃទី 1 ខែមេសា រដ្ឋ Rhode Island បានចាប់ផ្តើមការបន្តសិទ្ធិទទួលបានសម្រាប់ប្រជាជនរស់នៅរដ្ឋ Rhode Island ដែលមាន Medicaid។ ដូចដែលបានតម្រូវដោយច្បាប់សហព័ន្ធ រដ្ឋនឹងមិនបន្តសម្រាប់មនុស្សគ្រប់គ្នាក្នុងពេលតែមួយទេ។ អ្នកនឹងទទួលបានសេចក្តីជូនដំណឹងអំពីការបន្តនៅពេលណាមួយក្នុងអំឡុងឆ្នាំបន្ទាប់។ អ្នកអាចទទួលបានសេចក្តីជូនដំណឹងអំពីការបន្តរបស់អ្នកភ្លាមៗ ឬសេចក្តីជូនដំណឹងនោះអាចមកដល់នៅចុងឆ្នាំនេះ (គ្រួសារដែលមានកូននឹងមិនទទួលបានសេចក្តីជូនដំណឹងអំពីបន្តរហូតដល់ខែធ្នូ ឆ្នាំ 2023)។

អ្វីដែលសំខាន់បំផុតដែលត្រូវធ្វើគឺ**ត្រូវប្រាកដថាព័ត៌មានទំនាក់ទំនងរបស់អ្នកមានបច្ចុប្បន្នភាព។** យើងនឹងផ្ញើសេចក្តីជូនដំណឹងអំពីការបន្ត Medicaid របស់អ្នកទៅកាន់អាសយដ្ឋានដែលយើងមានសម្រាប់អ្នក។ ឬប្រសិនបើអ្នកបានជ្រើសរើសការទទួលយកសេចក្តីជូនដំណឹងរបស់អ្នកតាមប្រព័ន្ធអេឡិចត្រូនិក សេចក្តីជូនដំណឹងអំពីការបន្ត Medicaid របស់អ្នកនឹងមាននៅក្នុងគណនីរបស់អ្នកតាមរយៈ[www.healthyrhode.ri.gov](www.healthyrhode.ri.gov)។

BE READY.
STAY COVERED.

អ្នកអាចពិនិត្យមើល ឬធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នកដោយចូលមើល www.healthyrhode.ri.gov ឬតាមរយៈការឡុកចូលទៅក្នុងកម្មវិធីទូរសព្ទចល័តរបស់ HealthyRhode ។ បញ្ចូលឈ្មោះអ្នកប្រើ និងពាក្យសម្ងាត់របស់អ្នក បន្ទាប់មក៖

- ចុច “My Profile” (ប្រវត្តិរូបរបស់ខ្ញុំ)។ បន្ទាប់មកចុច “My Contact Information” (ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំ)។
- ពិនិត្យមើលឈ្មោះ អាសយដ្ឋានប្រៃសណីយ៍ លេខទូរសព្ទ និងអាសយដ្ឋានអ៊ីមែលរបស់អ្នក។ រក្សាទុករាល់ការផ្លាស់ប្តូរ។
- ប្រសិនបើអ្នកចង់ អ្នកអាចចុះឈ្មោះសម្រាប់សារជាអក្សរអំពីការធានារ៉ាប់រងរបស់អ្នក។ ចុច “My Contact Information” (ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំ) ហើយពិនិត្យមើល “Sign Up for Text Messages” (ចុះឈ្មោះសម្រាប់សារជាអក្សរ)។

អ្នកក៏អាចធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នកតាមរយៈទូរសព្ទផងដែរ។ ទូរសព្ទទៅលេខនៅលើបណ្ណធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកមានគម្រោង Neighborhood Health Plan of Rhode Island គម្រោង Tufts Health Plan (RITogether) ឬគម្រោង UnitedHealthcare Community Plan (UHCCP)។ អ្នកក៏អាចទូរសព្ទទៅ HealthSource RI តាមរយៈលេខ 1-855-840-4774 ឬ ក្រសួងសេវាមនុស្សជាតិតាមរយៈលេខ 1-855-697-4347។

ការបន្តជួយរដ្ឋក្នុងការបញ្ជាក់ថា អ្នករាល់គ្នាដែលមាន Medicaid នៅតែមានសិទ្ធិទទួលបាន។ ដើម្បីស្វែងរកកាលបរិច្ឆេទបន្ត Medicaid ដែលរំពឹងទុករបស់អ្នក សូមឡុកចូលទៅកាន់គណនីរបស់អ្នកតាមរយៈ healthyrhode.ri.gov ហើយរកមើល “My Renewal Information” (ព័ត៌មានអំពីការបន្តរបស់ខ្ញុំ)។

**វាជារឿងសំខាន់ក្នុងការដឹងថា អ្នកនៅតែមាន Medicaid ខណៈពេលដែលអ្នករង់ចាំសេចក្តីជូនដំណឹងអំពីបន្តរបស់អ្នក និងការកំណត់សិទ្ធិទទួលបាន។** នៅពេលដែលអ្នកបានទទួលសេចក្តីជូនដំណឹងអំពីការបន្ត Medicaid របស់អ្នកហើយ សូមពិនិត្យមើលវា និងផ្តល់ឯកសារណាមួយដែលបានស្នើសុំ**ត្រឹមកាលបរិច្ឆេទកំណត់**នៅលើសេចក្តីជូនដំណឹងរបស់អ្នក។ ដរាបណា អ្នកផ្តល់ព័ត៌មានដែលបានស្នើរសុំ**ត្រឹមកាលបរិច្ឆេទកំណត់** អ្នកនៅទទួលបានការរ៉ាប់រង ខណៈពេលដែលយើងកំណត់ថាតើអ្នកនៅតែមានសិទ្ធិទទួលបាន Medicaid ដែរឬអត់។ ប្រសិនបើយើងមិនស្នើសុំឯកសារ ឬព័ត៌មានណាមួយទេ អ្នកគ្រាន់តែពិនិត្យមើលព័ត៌មានដែលអ្នកឃើញនៅលើសេចក្តីជូនដំណឹងអំពីការបន្តរបស់អ្នកបានហើយ។ ប្រាប់ឱ្យយើងដឹងប្រសិនបើមានកំហុស ឬការផ្លាស់ប្តូរណាមួយដែលត្រូវធ្វើ។

ក្រុមការងាររបស់យើងត្រៀមខ្លួនជាស្រេចដើម្បីជួយអ្នក ប្រសិនបើអ្នកត្រូវការជំនួយ។ ទាក់ទងទៅ HSRI តាមរយៈលេខ 1-855-840-4774 ឬទូរសព្ទទៅ DHS តាមរយៈលេខ 1-855-697-4347។ អ្នកក៏អាចទទួលបានជំនួយពីទីភ្នាក់ងារនៅក្នុងសហគមន៍របស់អ្នកផងដែរ។ ស្វែងរកទីភ្នាក់ងារដែលនៅក្បែរអ្នកតាមរយៈwww.healthsourceri.com។ ដើម្បីស្វែងយល់បន្ថែមអំពីការបន្ត Medicaid និងមើលគំរូនៃសេចក្តីជូនដំណឹងអំពីការបន្ត សូមចូលមើល www.staycovered.ri.gov។

BE READY. STAY COVERED.

*សារសម្រាប់ព្រឹត្តិបត្រព័ត៌មានដែលបានផ្ញើទៅដៃគូ/អង្គការសហគមន៍*

# ការបន្ត Medicaid កំពុងដំណើរការ

*អ្វីដែលដៃគូសហគមន៍អាចធ្វើបានដើម្បីជួយប្រជាជនរស់នៅក្នុងរដ្ឋ Rhode Island ឱ្យត្រៀមខ្លួនជាស្រេច និងបន្តទទួលបានការធានារ៉ាប់រង។*

ការបន្ត Medicaid ប្រចាំឆ្នាំបានបន្តនៅថ្ងៃទី 1 ខែមេសា ហើយនឹងបន្តសម្រាប់ឆ្នាំបន្ទាប់។ ប្រជាជនរស់នៅរដ្ឋ Rhode Island ចំនួនច្រើនជាង 350,000 នាក់កំពុងតែចុះឈ្មោះចូល Medicaid។ សមាជិក Medicaid មួយចំនួនប្រហែលជាភ្លេចអំពីដំណើរការក្នុងការបន្ត ឬអ្នកផ្សេងទៀតដែលប្រហែលជាថ្មីចំពោះ Medicaid មិនបានធ្វើវាពីមុនមក។ ក្នុងនាមជាដៃគូសហគមន៍ដែលមានទំនុកចិត្ត អ្នកអាចជួយយើងខ្ញុំផ្សព្វផ្សាយអំពីការបន្ត Medicaid និងជួយឱ្យរដ្ឋ Rhode Island បន្តរក្សាអត្រាការធានារ៉ាប់រងដ៏ខ្ពស់របស់រដ្ឋ (ប្រហែល 97 ភាគរយ)។

នេះគឺជារឿង 5 យ៉ាងដែលអ្នកគួរដឹងនៅពេលដែលការបន្ត Medicaid កំពុងដំណើរការ៖

1. **ការបន្ត Medicaid បានចាប់ផ្តើមម្តងទៀតនៅថ្ងៃទី 1 ខែមេសា ឆ្នាំ 2023។** ការបន្តជួយរដ្ឋក្នុងការបញ្ជាក់ថាអ្នករាល់គ្នាដែលមាន Medicaid នៅតែមានសិទ្ធិទទួលបាន។ ការបន្តប្រចាំឆ្នាំបានបញ្ឈប់ដើម្បីជួយធ្វើឱ្យកាន់តែងាយស្រួលក្នុងអំឡុងគ្រាអាសន្នផ្នែកសុខភាពសាធារណៈសហព័ន្ធ COVID-19 ប៉ុន្តែឥឡូវនេះដំណើរការបានចាប់ផ្តើមឡើងវិញហើយ។
2. **អ្វីដែលសំខាន់បំផុតដែលសមាជិក Medicaid អាចធ្វើបាននៅពេលនេះ គឺធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់ពួកគេ ដូច្នេះរដ្ឋអាចផ្ញើជូនពួកគេនូវព័ត៌មានថ្មីៗសំខាន់ៗអំពីការធានារ៉ាប់រងរបស់ពួកគេ។** នេះគឺជារបៀបដែលសមាជិក Medicaid អាចធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់ពួកគេបាន៖
    a) តាមរយៈកុំព្យូទ័រ ឬទូរសព្ទស្មាតហ្វូន៖ ចូលមើល healthyrhode.ri.gov ឬទាញយកកម្មវិធីទូរសព្ទចល័តរបស់ HealthyRhode ។
    b) តាមរយៈទូរសព្ទ៖ ទូរសព្ទទៅលេខនៅលើបណ្ណធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកមានគម្រោង Neighborhood Health Plan of Rhode Island គម្រោង Tufts Health Plan (RITogether) ឬគម្រោង UnitedHealthcare Community Plan (UHCCP)។ អ្នកក៏អាចទូរសព្ទទៅ HealthSource RI តាមរយៈលេខ 1-855-840-4774 ឬ ក្រសួងសេវាមនុស្សជាតិតាមរយៈលេខ 1-855-697-4347។
    c) ដោយផ្ទាល់៖ បុគ្គលិកនៅការិយាល័យក្រសួងសេវាមនុស្សជាតិ (DHS) នៃរដ្ឋ Rhode Island អាចជួយដល់អតិថិជនបានដោយផ្ទាល់។ ចុចទីនេះ សម្រាប់បញ្ជីនៃការិយាល័យតំបន់របស់ក្រសួង DHS។
3. **មិនមែនគ្រប់គ្នាសុទ្ធតែនឹងទទួលបានការបន្តក្នុងពេលតែមួយនោះទេ។** សមាជិក Medicaid នឹងទទួលបានដំណឹងពីរដ្ឋ Rhode Island អំពីការធានារ៉ាប់រងរបស់ពួកគេចន្លោះពីពេលនេះ ដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2024។ *គ្រួសារដែលមានកូននឹងមិនទទួលបានសេចក្តីជូនដំណឹងអំពីការបន្តរហូតដល់ខែធ្នូ ឆ្នាំ 2023 ។* សមាជិកអាចស្វែងរកកាលបរិច្ឆេទបន្តប៉ាន់ស្មានរបស់ពួកគេដោយការឡុកចូលទៅកាន់គណនីរបស់ពួកគេតាមរយៈ healthyrhode.ri.gov ។

4. **គោលដៅរបស់រដ្ឋគឺដើម្បីធានាថា ប្រជាជនរស់នៅក្នុងរដ្ឋ Rhode Island បន្តទទួលបានការធានារ៉ាប់រង។** ប្រសិនបើការធានារ៉ាប់រង Medicaid របស់នរណាម្នាក់នឹងបញ្ចប់ដោយសារតែពួកគេលែងមានសិទ្ធិទទួលបានទៀតហើយ នោះពួកគេនឹងទទួលបានព័ត៌មានអំពីរបៀបចុះឈ្មោះក្នុងការធានារ៉ាប់រងសុខភាពដែលមានតម្លៃទាបតាមរយៈ HealthSource RI។
5. **អ្នកអាចជួយចែករំលែកព័ត៌មានអំពីការបន្ត Medicaid ជាមួយនឹងសមាជិកសហគមន៍។** ចុចទីនេះដើម្បីទាញយកធនធានដែលអាចចែករំលែក និងបោះពុម្ពបានជាច្រើនភាសា។

ដើម្បីស្វែងយល់បន្ថែមអំពីការបន្ត Medicaid សូមចូលមើល staycovered.ri.gov។

---

*សារសម្រាប់ព្រឹត្តិបត្រព័ត៌មានដែលបានផ្ញើទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាព*

**ជួយអ្នកជំងឺរៀបចំសម្រាប់ការបន្ត Medicaid**

ការបន្ត Medicaid ប្រចាំឆ្នាំបានធ្វើបន្តនៅថ្ងៃទី 1 ខែមេសា។ សមាជិក Medicaid នឹងទទួលបានដំណឹងពីរដ្ឋ Rhode Island អំពីការធានារ៉ាប់រងរបស់ពួកគេចន្លោះពីពេលនេះ ដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2024។ មានរឿងសំខាន់ៗមួយចំនួនដែលអ្នកអាចធ្វើបាន ដើម្បីជួយធ្វើឱ្យប្រាកដថា អ្នកជំងឺរបស់អ្នកបន្តទទួលបានការធានារ៉ាប់រង។

- **ចែករំលែកព័ត៌មាននៅកន្លែងរង់ចាំ។** គេហទំព័រនេះមានខិត្តបណ្ណដែលអាចទាញយកបាន ព្រមទាំងផ្ទាំងរូបភាពដែលមានព័ត៌មានអំពីការបន្ត Medicaid ជាច្រើនភាសា។
- **ពិភាក្សាជាមួយអ្នកជំងឺរបស់អ្នកដែលមាន Medicaid។** ត្រូវប្រាកដថា ពួកគេដឹងថាដំណើរការនេះកំពុងចាប់ផ្តើមម្តងទៀត។ ជូនដំណឹងឱ្យពួកគេដឹងថា ការធានារ៉ាប់រងរបស់ពួកគេនៅតែសកម្មក្នុងអំឡុងពេលនៃដំណើរការនេះ ហើយរដ្ឋនឹងបញ្ជូនព័ត៌មានឱ្យពួកគេនៅពេលដែលដល់វេនរបស់ពួកគេក្នុងការបន្ត។
- **លើកទឹកចិត្តអ្នកជំងឺឱ្យប្រាកដថាព័ត៌មានទំនាក់ទំនងរបស់ពួកគេមានបច្ចុប្បន្នភាព** ដូច្នេះរដ្ឋអាចផ្ញើជូនពួកគេនូវសេចក្តីជូនដំណឹងសំខាន់ៗអំពីការធានារ៉ាប់រងរបស់ពួកគេ។ នេះគឺជារបៀបដែលពួកគេអាចធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ពួកគេ៖
    - តាមរយៈកុំព្យូទ័រ ឬទូរសព្ទស្មាតហ្វូន៖ ចូលមើល healthyrhode.ri.gov ឬទាញយកកម្មវិធីទូរសព្ទចល័តរបស់ HealthyRhode ។
    - តាមរយៈទូរសព្ទ៖ ទូរសព្ទទៅលេខនៅលើបណ្ណធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកមានគម្រោង Neighborhood Health Plan of Rhode Island គម្រោង Tufts Health Plan (RITogether) ឬគម្រោង UnitedHealthcare Community Plan (UHCCP)។ អ្នកក៏អាចទូរសព្ទទៅ HealthSource RI តាមរយៈលេខ 1-855-840-4774 ឬ ក្រសួងសេវាមនុស្សជាតិតាមរយៈលេខ 1-855-697-4347។
    - ដោយផ្ទាល់៖ បុគ្គលិកនៅការិយាល័យក្រសួងសេវាមនុស្សជាតិ (DHS) នៃរដ្ឋ Rhode Island អាចជួយដល់អតិថិជនបានដោយផ្ទាល់។ ចុចទីនេះ សម្រាប់បញ្ជីនៃការិយាល័យតំបន់របស់ក្រសួង DHS។

ដើម្បីស្វែងយល់បន្ថែមអំពីការបន្ត Medicaid ឬទាញយកឯកសារព័ត៌មានជាច្រើនភាសា សូមចូលមើល staycovered.ri.gov។